# **កិច្ចប្រជុំពិភាក្សារវាងក្រសួង និង ប្រតិបត្តិករទូរស័ព្ទចល័ត**

# **ក្រោមអធិបតេយ្យភាពឯកឧត្តម សូរ ឃុន**

# **រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

# **ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១១**

**ឯកឧត្តម សូរ ឃុន** *បានលើកឡើងនូវចំណុចសំខាន់ៗដូចខាងក្រោម៖*

- *កោតសរសើរដល់គ្រប់ប្រតិបត្តិករទាំងអស់ចំពោះការរីកចំរើននៃអត្រាអ្នកប្រើប្រាស់កើនឡើងគួរអោយកត់សំគាល់ក្នុងដំឡុងពេលប៉ុន្មា នឆ្នាំចុងក្រោយ ។*
- *ប្រទេសកម្ពុជាមានទំហំតូចតែចំនួនប្រតិបត្តិករច្រើន*
- *កិច្ចសហការណ៍រវាងប្រតិបត្តករ និងប្រតិបត្តករមានដំណើរការទៅយ៉ាងរលូន ក៏ដូចគ្នាជាមួយក្រសួងប.ទ.ផងដែរ ។*
- *រាល់លិខិតបទដ្ឋានដែលរៀបចំដោយក្រសួងគឺ ដើម្បីសម្របសម្រួលការងាររបស់ប្រតិបត្តិករអាចដំណើរការទៅដោយរលូន ប៉ុន្តែក៏មាននូវចំណុចចន្លោះប្រហោងផងដែរចាំបាច់ត្រូវធ្វើការកែលំអរជាបន្តបន្ទាប់ ។*
- *ចំពោះលិខិតបទដ្ឋានរបស់ក្រសួង និងរដ្ឋាភិបាល ក្រសួងសង្កេតឃើញថា ប្រតិបត្តករមួយចំនួនបានអនុវត្តគោរពតាមល្អ ប៉ុន្តែមួយចំនួនមិនបានគោរពតាម ។*
- *បញ្ហាគ្រប់ប្រតិបត្តិករទាំងអស់គួរជៀសវាងគឺការប្តឹងគ្នាទៅវិញ ទៅមក ។*
- *ចំពោះបញ្ហារវាងប្រតិបត្តិករ និងប្រតិបត្តិករទាំងអស់គួររកដំណោះស្រាយដ៏ល្អក្នុងការពិភាក្សាគ្នាជាទ្វេភាគី ឬក៏ ពហុភាគីជាមុនសិន មុននឹងសំរេចចិត្តប្តឹងផ្តល់គ្នា។*
- *គ្រប់ប្រតិបត្តិករទាំងអស់គួរពិនិត្យមើលលើគុណភាពនៃសេវារបស់អោយបានល្អ ។*
- *ចំពោះលិខិតស្នើសុំការអនុញ្ញាតិផ្សព្វផ្សាយ មកក្រសួងគួរធ្វើឡើងតាមពេលវេលាសមរម្យ។*
- *ជាទីបញ្ចាប់* **ឯកឧត្តម** *បានផ្សព្វផ្សាយរបាយការណ៍កិច្ចប្រជុំរដ្ឋមន្ត្រីទូរគមនាគមន៍អាស៊ានលើកទី១០ ដល់គ្រប់ប្រតិបត្តិករទាំងអស់លើទិសដៅសម្រាប់ការអភិវឌ្ឍន៍ នូវគំរោងមេអាស៊ាន* ASEAN ICT Masterplan *ឆ្នាំ២០១៥ ។*
- *លើសពីនេះទៀត* **ឯកឧត្តម** *បានលើកឡើងថា រាជរដ្ឋាភិបាលពុំមាន គោលការណ៍បិទនូវគេហទំព័រមួយចំនួននោះទេ ប៉ុន្តែជាការសំណូមពររបស់* **ឯកឧត្តម** *ដល់គ្រប់ប្រតិបត្តិករទាំងអស់ជួយសហការណ៍ទប់ស្កាត់លើគេហទំព័រមួយចំនួន ដែលប៉ះប៉ាល់ដល់ សិលធម៌ប្រពៃណីខ្មែរ និងរាជរដ្ឋាភិបាល តាមការប្រើប្រាស់ប្រព័ន្ធ* Internet *រួម ។*
- *ស្នើសុំអោយគ្រប់ប្រតិបត្តិករទាំងអស់ជួយសហការណ៍ផ្តល់របាយការណ៍អោយបានទាន់ពេលវេលា ដើម្បីអោយក្រសួងមានលទ្ធភាពផ្តល់របាយការណ៍បន្តជូនរាជរដ្ឋាភិបាល។*

--------------------